# ការអំពាវនាវដល់ព្រះនាមព្រះអម្ចាស់

រ៉ូម ១០:៩ បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោស ឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត ។

**ចាប់ផ្តើមថ្ងៃថ្មី ហើយការអំពាវនាវដល់ព្រះនាមព្រះអម្ចាស់**

បន្ទាប់ពីយើងក្រោកឡើងនៅពេលព្រឹកព្រលឹម យើងគួរតែធ្វើអ្វីគ្រប់យ៉ាងដោយនូវវិញ្ញាណរបស់យើង ។ យើងត្រូវតែចាប់ផ្តើមថ្ងៃថ្មី ដោយរស់នៅ និងដើរនៅក្នុងវិញ្ញាណរបស់យើង។ ប្រសិនបើយើងក្រោកឡើងដោយរបៀបធូលុង យើងនឹងបង្ហួចថ្ងៃនោះពេញមួយថ្ងៃ។ រឿងប្រសើរបំផុតដែលយើងត្រូវធ្វើ បន្ទាប់ពីក្រោកឡើងនៅពេលព្រឹកព្រលឹម គឺអំពាវនាវដល់នាមព្រះអម្ចាស់ពីព្រោះពេលដែលយើងអំពាវនាវ ៖ ”អូរះអម្ចាស់យេស៊ូ” នោះយើងនឹងស្ថិតនៅក្នុងវិញ្ញាណ (១ ករ .១២: ៣) ។ ការអំពាវនាវដូចនេះ នឹងនាំយើងចេញពីរឿងផ្សេងៗ ចូលទៅក្នុងវិញ្ញាណរបស់យើងវិញ ។

បើខ្ញុំហៅឈ្មោះអ្នកណាម្នាក់ ដែលគាត់មានជីវិតរស់នៅ និងមានវត្តមាននៅ អ្នកនោះ ប្រាកដជានឹងមករកខ្ញុំ។ យ៉ាងណាមិញ ព្រះអម្ចាស់យេស៊ូទ្រង់ជាព្រះដ៏ពិត មានព្រះជន្មរស់ និងមានវត្តមានគង់នៅ ហើយទ្រង់តែងតែ គង់នៅជិតជានិច្ច ដូច្នេះ ពេលណាដែលយើងអំពាវនាវដល់ទ្រង់ ទ្រង់ប្រាកដជានឹងយាងមកឯយើង ។ តើអ្នកចង់ទទួលអំណរវត្តមានរបស់ព្រះអម្ចាស់ និងភាពបរិបូរណ៍គ្រប់ទាំងអស់របស់ទ្រង់ឬទេ? មធ្យោបាយប្រសើរបំផុត ដើម្បីបទពិសោធវត្តមាន និងភាពបរិបូរណ៍របស់ទ្រង់ គឺអំពាវនាវដល់ព្រះនាមទ្រង់។

**អំពាវនាវថល់ព្រះអម្ចាស់ថាក្រមថ នចេញពីចិត្តបំបរិសុទ្ធ**

**ថារៀងរាល់ថ្ងៃ ដរាបណាយើងនៅមានជីវិត**

តើយើងអំពាវនាវព្រះនាមព្រះអម្ចាស់ ដោយរបៀបណា? យើងត្រូវការអំពាវនាវដល់ព្រះនាមទ្រង់ដោយចិត្តដ៏បរិសុទ្ធ (២ធម .២:២២)។ ចិត្តរបស់យើង ដែលជាប្រកពក្នុងការអំពាវនាវរបស់យើងនោះ គឺត្រូវតែបរិសុទ្ធ មិនស្វែងរកអ្វីផ្សេងក្រៅពីព្រះអម្ចាស់ ។ យើងក៏ត្រូវអំពាវនាវដល់ព្រះនាមទ្រង់ ដោយបបូរមាត់ដ៏បរិសុទ្ធដែរ (សផ .៣៩, NASB)។ យើងត្រូវប្រុងប្រយ័ត្ន ចំពោះពាក្យសម្តីរបស់យើង ពីព្រោះការនិយាយលេង គឺជាអ្វីមួយដែលធ្វើឱ្យបបូរមាត់យើង ស្មោកគ្រោកបំផុត ។ប្រសិនបើបបូរមាត់យើងត្រឡប់ជាមិនបរិសុទ្ធ ដោយព្រោះ ការនិយាយលេង នោះយើងនឹងពិបាកអំពាវនាវដល់ព្រះអង្គ ។

ការអំពាវនាវដល់ព្រះនាមព្រះអង្គ គឺជាការស្រូបយកទ្រង់ ហើយការស្រូបយកទ្រង់នោះ គឺជាការជីកព្រះអង្គ។ ផ្លូវដើម្បីជីកព្រះពីព្រះវិញ្ញាណតែមួយ គឺអំពាវនាវ "អូព្រះអម្ចាស់យេស៊ូ! " ។ ប្រសិនបើយើងស្រេក ចូរអំពាវនាវដល់ព្រះនាមព្រះអង្គចុះ ។ យើងអាចនឹងស្រេក នៅគ្រប់ពេលវេលា គ្រប់ទីកន្លែង និងសូម្បីតែនៅពេលដែលយើងកំពុងបើកបរ ។ យើងអាចអំពាវនាវដល់ព្រះអង្គ និងទទួលទឹកដ៏រស់បាន ។ ចូរសាកល្បងឥឡូវ នោះអ្នកនឹងប៉ះពាល់ ។ ការនេះ សាមញ្ញណាស់ ហើយក៏ជាការដំណើរជីវិតគ្រិស្ទានរបស់យើងដែរ ។ ជីវិតគ្រិស្ទានរបស់យើង ត្រូវតែជាជីវិតនៃការអំពាវនាវដល់ព្រះនាមទ្រង់ ។

អូរ ព្រះយេស៊ូ  អូរ ព្រះយេស៊ូ

ហៅព្រះនាម ទ្រង់ ផ្អែមជាប់ចិត្ត

ប្រសេីរជាងស្រា  ផ្អែមជាងទឹកឃ្មុំ

អូរ ព្រះយេស៊ូ អាម៉ែន